**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ......១១៣.......................ក.ប/សជណា

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១២៨ ទិវាពលកម្មអន្តរជាតិ

## ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាគមនិយោជក និងនិយោជក សហភាពសហព័ន្ធសហជីព និងសហព័ន្ធសហជីព ព្រមទាំងកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ឱ្យបានជ្រាបថា យោងអនុក្រឹត្យលេខ៨៨៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីប្រក្រតីទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៤ និងប្រកាសលេខ ២៨៣ កប/ប្រក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ សូមអស់លោក-លោកស្រី យកចិត្តទុកដាក់នូវប្រការដូចខាងក្រោម៖

ទី-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តទាំងអស់ ត្រូវណែនាំឱ្យមានការរៀបចំប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី១២៨ ទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ ប្រកបដោយភាពអធិកអធមស័ក្តិសមជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ ដោយត្រូវតាក់តាំងឱ្យមានការចងបដាពាក្យស្លោក នៅតាមដងផ្លូវសំខាន់ៗ មន្ទីរនានា និងសហគ្រាស គ្រឹះស្ថានរាជធានី-ខេត្តរបស់ខ្លួន។

គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងសហព័ន្ធសហជីព គប្បីតាក់តាំងពិធីជួបជុំសំណេះសំណាលអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ នៅតាមសហគ្រាស គ្រឹះស្ថាន ទីស្នាក់ការសហព័ន្ធសហជីព ដើម្បីផ្សព្វផ្សាយសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** សារាចរណែនាំរបស់រាជរដ្ឋាភិបាល និងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងប្រារព្ធពិធីកំសាន្តសប្បាយរីករាយតាមរូបភាព និងលទ្ធភាពជាក់ស្តែង។

ទន្ទឹមនឹងនេះ អស់លោក-លោកស្រី ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចថែរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មវិធីសំណេះសំណាល និងសប្បាយរីករាយរបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងក្នុងមូលដ្ឋាន។

២-គ្រប់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ត្រូវចាត់ចែងឱ្យមានការឈប់សម្រាក នៅថ្ងៃទី០១ខែឧសភា ឆ្នាំ២០១៨។ ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាសគ្រឹះស្ថានមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃឈប់បុណ្យនេះ ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានត្រូវសម្របសម្រួលជាមួយកម្មករនិយោជិតឱ្យធ្វើការដោយស្ម័គ្រចិត្ត។ កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់បុណ្យនេះ មានសិទ្ធិទទួលនូវការឈប់សម្រាកសងនៅថ្ងៃណាមួយក្នុងសប្តាហ៍ ឬទទួលប្រាក់បំណាច់ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

៣-សហព័ន្ធសហជីព និងសហជីពតាមសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួល និងសហការជាមួយនិយោជក ដើម្បីចាត់តាំងការជួបជុំសំណេះសំណាលតាមសហគ្រាស គ្រឹះស្ថាន ទទួលអំណរទិវាពលកម្មអន្តរជាតិថ្ងៃទី០១ ខែឧសភា ឬចាត់តាំងពិធីកំសាន្តសប្បាយរីករាយតាមរូបភាពផ្សេងៗ និងតាមលទ្ធភាពរៀងៗខ្លួន ដើម្បីបង្កបរិយាកាសសាមគ្គីភាពនៅតាមសហគ្រាស គ្រឹះស្ថាន ។

៤-សហព័ន្ធសហជីព និងសហជីពតាមសហគ្រាស គ្រឹះស្ថាន កុំឆ្លៀតយកឱកាសទិវាពលកម្មអន្តរជាតិថ្ងៃទី០១ ខែឧសភា ដែលជាថ្ងៃបុណ្យការងារ និងជាថ្ងៃឈប់សម្រាកការងាររបស់កម្មករនិយោជិត ដើម្បីបង្កនូវបាតុភាពទាំងឡាយណា ដែលនាំឱ្យមានអំពើហិង្សា ឬខានដល់គោលបំណងខាងលើឡើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាគមនិយោជក និងនិយោជក ព្រមទាំង សហព័ន្ធសហជីព និងកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ និងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៨

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព កម្មករនិយោជិត
"ដើម្បីជ្រាប និងអនុវត្ត"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ